ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　　　　　　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី　　　　　　　　　៣៣៣*៣៣

លេខៈ ៧៦

ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០២　　　　　សាលក្រមប្រជារាស្ត្រខ្មែរ

**សាលដីកា**　　　　　　　　　　　　**តុលាការកំពូល**

លេខៈ ៣១៥　　　　　　　　បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៥

ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥　　　ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ខិន** | **មុន្នី** | ជាប្រធាន |
| ២-លោក | វឿល | មួន | ជាចៅក្រម |
| ៣-លោក | ឈឹម | ស៊ីផល | ជាចៅក្រម |
| ៤-លោក | សោម | សិរីវឌ្ឍ | ជាចៅក្រម |
| ៥-លោក | ម៉ុង | មុន្នីចរិយា | ជាចៅក្រមរបាយការណ៍ |

ក្រឡាបញ្ជី

លោក **អ៊ិ** **សុខុន**

តំណាងមហាអយ្យការ

លោក **ឈួន ចាន់ថា** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៩២"ក"ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៨១៣ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ **ហ៊ុច សំ** (ជាចុងបណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅក្រុមទី១៥ ភូមិក្តារ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។

មានមេធាវីលោក ស៊ឹម ស៊ីថាន ។

ចុងចម្លើយឈ្មោះ **ទី ចេង** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅក្រុមទី១៥ ភូមិក្តារ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ។

ផ្ទេរសិទ្ធិឱ្យអ្នកស្រី ហេង ធីតា ។

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារដី និងរុះរើសំណង់ចេញពីដីទំនាស់.

បានឃើញបណ្ដឹងសាទុក្ខលេខ ៧៧ ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ២០០១ របស់ឈ្មោះលីធីតា ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៩២"ក" ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៧៦ ចុះថ្ងៃទី២៥ ខែមិនា ឆ្នាំ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី០៨-៤-១៩៩៩ របស់ភាគីដើមចោទឈ្មោះហ៊ិន វន និងឯកសារនៃអង្គហេតុបានបញ្ជាក់ថា ដើមចោទប្ដឹងទាមទារកាន់កាប់ និងគ្រប់គ្រងដីភូមិទំហំ ២៨០ម[២] ដែលមានទីតាំងស្ថិតនៅភូមិក្បាវ ឃុំត្រែង ស្រុករតនមណ្ឌល ខេត្តបាត់ដំបង ពីចុងចំលើយឈ្មោះធីហេងដែលបានរំលោភយកដីកម្មសិទ្ធិរបស់ខ្លួនដោយបានសំអាងហេតុថា ដីទំនាស់នេះខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៧៩ រហូតមក មានសង់លំនៅដ្ឋានដាំដំណាំ ។ លុះដល់ឆ្នាំ១៩៨៩ ដោយស្រុកទេសមានសង្គ្រាម ក្រុមគ្រួសារខ្លួនក៏បានភាសសឹកទៅឆ្ងាយ ហើយនៅឆ្នាំ១៩៩៦ ពេលស្រុកមានសន្តិភាពក្រុមគ្រួសារខ្លួនក៏ត្រឡប់ចូលស្រុកវិញ ពេលនោះខ្លួនឃើញឈ្មោះធី ហេង បានសាងសង់ផ្ទះ និងរស់នៅលើដីរបស់ខ្លួន ។ នៅថ្ងៃទី០២-៣-១៩៩៧ ខ្លួនបានទៅសុំដីនៅខាងក្រោយ តែឈ្មោះ ធី ហេង មិនព្រមឱ្យ ពេលនោះក៏មានការប្ដឹងគ្នាទៅភូមិ ។ ដីទំនាស់នេះមានការដោះស្រាយជាបន្តបន្ទាប់នៅថ្នាក់រដ្ឋអំណាចមូលដ្ឋានពីថ្នាក់ភូមិរហូតដល់ស្រុក តែពុំអាចផ្សះផ្សាគ្នាបាន ។ ដីទំនាស់មានព្រំប្រទល់គឺ :

- ខាងជើងទល់ផ្លូវជាតិលេខ ១០A
- ខាងលិចទល់ផ្លូវជាតិលេខ ១០B
- ខាងកើតទល់ដីរបស់ឈ្មោះប៊ិច ជឿន
- ខាងត្បូងទល់ដីរបស់ឈ្មោះជិម យិ ។

ដោះសារចំពោះបណ្ដឹងទាមទាររបស់ដើមចោទ ភាគីចុងចោទឈ្មោះធី ហេង បានបញ្ជាក់ថា ដីទំនាស់នេះ ខ្លួនបានទិញពីឈ្មោះសោម សុខុម ជានគរបាលក្នុងតំលៃ៣៣០០០០រ ដោយមានកិច្ចសន្យាត្រឹមត្រូវ ។ កាលពីមកស្នាក់នៅដំបូងនៅឆ្នាំ១៩៩៧ ដីនេះជាដីព្រៃ និងមានបង្កប់មីន ដូចនេះខ្លួនជាអ្នកកាប់ឆ្ការ និងដោះមីនដោយខ្លួនឯង ។ លុះដល់ឆ្នាំ១៩៩៨ ទើបឈ្មោះហ៊ិន វន បានប្ដឹងទាមទារដីនេះពីខ្លួន ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ២៣៧ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៩ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

I-ក-ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ១៩៩៩ និងសំណូមពរនាពេលសាវនាការ របស់ដើមចោទឈ្មោះហ៊ិន វន ប្តឹងសុំគ្រប់គ្រងកាន់កាប់ដីទំនាស់ជាកម្មសិទ្ធិ និងប្តឹងសុំឱ្យចុងចំលើយឈ្មោះធី ហេង រុះរើផ្ទះចេញពីដីទំនាស់ដោយឧបត្ថម្ភការរុះរើ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

ខ-ទទួលសំណូមពររបស់ចុងចំលើយឈ្មោះធី ហេង ប្តឹងសុំគ្រប់គ្រងកាន់កាប់ដីទំនាស់ជាកម្មសិទ្ធិទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

II-ប្រគល់ដីទំនាស់ស្ថិតនៅភូមិភ្នាវ ឃុំត្រែង ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបងឱ្យដល់ដើមចោទឈ្មោះហ៊ិន វន គ្រប់គ្រងកាន់កាប់ជាកម្មសិទ្ធិស្របច្បាប់ គិតយកជាមូលដ្ឋានតាមប្លង់ទីតាំងបង្ហាញដីទំនាស់ចុះថៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៩ របស់មន្ទីរសុរិយោដីខេត្តបាត់ដំបងក្នុងទំហំ FCDEF មានផ្ទៃក្រឡា ២៩១ម$^2$ ដែលមានជ្រុង CD=៣៣,៩៤ម, DE=៧,៨០ម, EF=២៩,៥០ម,និង FC=១៣,០០ម និងឱ្យចុងចំលើយឈ្មោះធី ហេង រុះរើផ្ទះចេញពីដីនេះដោយឱ្យដើមចោទឈ្មោះហ៊ិន វន ឧបត្ថម្ភការរុះរើចំនួន ២០០០បាតប្រាក់ថៃចាប់ពីថ្ងៃដែលសាលក្រមចូលជាស្ថាពរ ។

II-ឱ្យចុងចំលើយឈ្មោះធី ហេង បង់ប្រាក់ប្រដាប់ក្តីគឺ :

- ពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង : ១៨០០រ
- រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ : ២០០រ
- ចំណាយស៊ើបសួរ : ៥០០០រ សរុប ៧០០០រ ។

ប្រាក់នេះបានកាត់យកពីប្រាក់ដែលដើមចោទបានបង់រួចហើយ កាលបើហួសឧទ្ធរណ៍ ឱ្យចុងចំលើយសងប្រាក់ចំនួន ៧០០០រ ទៅដើមចោទវិញ និងឱ្យចុងចំលើយឈ្មោះធី ហេង បង់ពន្ធសមាមាត្រចំនួន ១២.០០០រ ប្រាក់នេះកាត់៨០% បង់ចូលថវិការដ្ឋ សល់ ២០% ដាក់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងព្រះរាជាណាចក្រកម្ពុជា ។

តាមអនុក្រឹត្យលេខ ២៥អនក្រ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៨៩ .

តាមមាត្រា ៣,៥,១៩,២០,២៨,៦២,៦៤,៦៥,៦៨,៧៤ នៃច្បាប់ភូមិបាល ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ១០០ក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ និងតាមច្បាប់ស្តីពីប្រាក់ប្រដាប់ក្តីដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ។

IV-សាលក្រមនេះជំនុំជំរះ ប្រកាសជាសាធារណៈចំពោះមុខគូក្តី ។

បើកផ្លូវឧទ្ធរណ៍ពីរខែ គិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ១១៥ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់ឈ្មោះធីហេង ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៣៧ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៩ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៨៦"ក"ចុះថ្ងៃទី២៥ ខែមេសាឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ១១៥ ចុះថ្ងៃទី០៨-១១-១៩៩៩ របស់ឈ្មោះ ធី ហេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលក្រមលេខ ២៣៧ ចុះថ្ងៃទី២០-១០-១៩៩៩ របស់តុលាការខេត្តបាត់ដំបង ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធប្តឹងចំនួន ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះចំនួន ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការចំនួន ៥០០០៛ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខ ហ៊ិន វន កំបាំងមុខ ធី ហេង ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ៥១ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០០ របស់ឈ្មោះធីហេង ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៨៦ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៩២"ក" ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី០៨-៥-២០០០ របស់ឈ្មោះធី ហេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីកាលេខ៨៦"ក"ចុះថ្ងៃទី២៥-០៤-២០០០ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈកំបាំងមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ គិតចាប់ពីថ្ងៃទទួលដំណឹង ។

បានឃើញបណ្តឹងសាទុក្ខលេខ ៧៧ ចុះថ្ងៃទី១៥ ខែមិនា ឆ្នាំ២០០១ របស់ឈ្មោះលីធីតា ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៩២"ក" ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះ ធី ហេង ។

បានឃើញសារណាតបចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០២ របស់ឈ្មោះហ៊ិន វន ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : រឿងនេះជាវិវាទប្តឹងទាមទារដី សូមក្រុមប្រឹក្សាជំនុំជំរះសំរេច ។

បានស្តាប់ចំលើយរបស់ឈ្មោះហេង ធីតា នាពេលសវនាការថា : ដីនេះខ្លួនបានទិញពីប៉ូលីសឈ្មោះសោម សុខុម ជាដីព្រៃនៅឆ្នាំ១៩៨៧ ទើបតែនៅឆ្នាំ១៩៩៨-១៩៩៩ ទើបឈ្មោះហ៊ិន វន ប្តឹងទាមទារ ។ លើដីនេះខ្លួនបានធ្វើផ្ទះរស់នៅ និងលក់ដូរនៅមុខផ្ទះ ។

សុំឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង ។

បានស្តាប់ចំលើយរបស់ឈ្មោះហ៊ិន វន នាពេលសវនាការថា :ដីនេះខ្លួនរស់នៅតាំងពីឆ្នាំ ១៩៧៩ រហូតដល់ឆ្នាំ១៩៨៩ ប្រទេសជាតិកើតសង្គ្រាម រដ្ឋាភិបាលបានជំលៀសចេញពីភូមិមួយរយៈសិន ហើយនៅឆ្នាំ១៩៩៦ ប្រទេសជាតិមានសន្តិភាព ខ្លួនក៏ត្រឡប់មកវិញ ស្រាប់តែឃើញឈ្មោះ ធី ហេង ចូលរស់នៅ ។ សុំតំកល់សាលដីកាសាលាឧទ្ធរណ៍ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកស៊ឹម ស៊ីថាន ជាមេធាវីការពារឱ្យដើមចោទ បានលើកឡើងថា : ដីទំនាស់នេះ កូនក្តីខ្លួនកាន់កាប់តាំងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ ក៏ចាកចេញមួយរយៈសិន ដោយប្រទេសមានសង្គ្រាម ។

សំណូមពរសុំឱ្យតុលាការកំពូលសំរេចតំកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូលល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចំលើយដោះសាររបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ .
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៧៧ ចុះថ្ងៃទី១៥-០៣-២០០១ របស់ឈ្មោះ ធី ហេង បានធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការបញ្ជាក់របស់រដ្ឋអំណាចមូលដ្ឋាន និង ចំលើយរបស់សាក្សីនៃទីតាំងដីទំនាស់ គឺជាភស្តុតាងបញ្ជាក់ថា ភាគីដើមចោទឈ្មោះហ៊ិន វន ពិតជាបានកាន់កាប់ដីទំនាស់ជាប់ជាអចិន្ត្រៃយ៍រហូតដល់ឆ្នាំ១៩៨៩ និងក្រោយមកបានបោះបង់មួយរយៈដោយហេតុផលសង្គ្រាមប្រាកដមែន រីឯចុងចំលើយ បានលទ្ធកម្មដោយសារកិច្ចសន្យាចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៩៧ ទិញដីពីឈ្មោះសោម សុខុម មុខរបរនគរបាល ដែលពុំមែនជាម្ចាស់ដើមឡើយ ដូចនេះចុងចំលើយពុំមានសិទ្ធិលើដីទំនាស់នេះទេ តាមការកំណត់នៃមាត្រា១៨០ នៃច្បាប់ភូមិបាលឆ្នាំ១៩៩២ ។

- យល់ឃើញថា ការដែលលោក ហ៊ិន វន ចាកចេញពីដីទំនាស់ពីឆ្នាំ១៩៨៩ ដោយសារសង្គ្រាមនោះ គឺជាករណីប្រធានស័ក្ក ពុំអាចចាត់ទុកថាលោកបោះបង់ដីនេះចោល ដោយឆន្ទៈផ្ទាល់ឡើយ ។

- យល់ឃើញថា ការដែលអ្នកស្រីហេង ធីតា ចុងចំលើយ លើកឡើងនាសវនាការនេះថា អ្នកស្រីបានទិញដីនេះ ហើយបានកាប់ឆ្ការ និងដាំដំណាំរហូតបានទទួលផលនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា ពុំមានភស្តុតាងណាបញ្ជាក់ថា ឈ្មោះសោម សុខុម ដែលជាអ្នកលក់ដីឱ្យខ្លួនជាម្ចាស់ដីនោះឡើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩២"ក"ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ ។

### ហេតុដូចនេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ៧៧ចុះថ្ងៃទី១៥-០៣-២០០១ របស់ឈ្មោះធី ហេង ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ៩២"ក" ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលភាគីលោក ហ៊ិន វន បានបង់នៅតុលាការកំពូលចំនួន ១៩០០០៛ គឺ :

-ពន្ធចុះបញ្ជីក្តីនិងពន្ធហ្មឹងចំនួន៨.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់

ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

បង្គាប់ឱ្យភាគីលោក ធី ហេង សងប្រាក់ចំនួន ១៩.០០០៛ នេះទៅឈ្មោះហ៊ិន វន វិញ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ ។